ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អគ្គនាយកដ្ឋានពន្ធដារ
នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ......១៦១៧.........អពដ

រាជធានីភ្នំពេញ ថ្ងៃទី២០ ខែធ្នូ ឆ្នាំ ២០១២

# សេចក្តីជូនដំណឹង
## ស្តីពី
## ការបញ្ឈប់ការលក់ឯកសារលិខិតប្រកាសពន្ធគ្រប់ប្រភេទ

អគ្គនាយកដ្ឋានពន្ធដារ នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សូមជូនដំណឹងដល់អ្នកឧកញ៉ា លោកឧកញ៉ា លោក-លោកស្រី ជាអភិបាល ឬបណ្ណាធិការសហគ្រាស អ្នកជាប់ពន្ធ និងសាធារណជនទាំងអស់ ជ្រាបថា ចាប់ពីថ្ងៃទី ០១ ខែ មករា ឆ្នាំ ២០១៣ នេះតទៅ អគ្គនាយកដ្ឋានពន្ធដារ នឹងបញ្ឈប់ការលក់ឯកសារលិខិតប្រកាសពន្ធគ្រប់ប្រភេទទាំងអស់ជូនដល់អ្នកជាប់ពន្ធ។

លិខិតប្រកាសពន្ធគ្រប់ប្រភេទ នឹងត្រូវបានដាក់បង្ហោះនៅលើគេហទំព័រ www.tax.gov.kh របស់អគ្គនាយកដ្ឋានពន្ធដារ សម្រាប់អ្នកឧកញ៉ា លោកឧកញ៉ា លោក-លោកស្រី ទាញយក (download) មកប្រើប្រាស់ដើម្បីបំពេញកាតព្វកិច្ចសារពើពន្ធ តាមចំនួនដែលត្រូវបានកំណត់នៅក្នុងបទប្បញ្ញត្តិស្តីពីសារពើពន្ធ។ ក្នុងករណីអ្នកជាប់ពន្ធពុំមានលទ្ធភាពចូលទៅកាន់គេហទំព័រនេះ អគ្គនាយកដ្ឋានពន្ធដារ នឹងផ្តល់ជូនលិខិតប្រកាសពន្ធគ្រប់ប្រភេទដោយឥតគិតថ្លៃ នៅអគ្គនាយកដ្ឋានពន្ធដារ និងគ្រប់សាខាពន្ធដារខេត្ត-ខណ្ឌ។

អគ្គនាយកដ្ឋានពន្ធដារ នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សង្ឃឹមជឿជាក់ថា ការកែសម្រួលការផ្តល់សេវាថ្មីពីអគ្គនាយកដ្ឋានពន្ធដារ នឹងជួយសម្រួលដល់អ្នកជាប់ពន្ធទាំងអស់ ក្នុងការបំពេញកាតព្វកិច្ចសារពើពន្ធ ជាក់ជាពុំខាន។

ប្រតិភូរាជរដ្ឋាភិបាល
ទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធដារ

គង់ វិបុល

អាគារកែងមហាវិថី សហព័ន្ធរុស្ស៊ី (១១០) និងម៉ៅសេទុង (២៤៥) សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ
CORNER RUSSIAN FEDERATION & MAO TSETONG BLVD. TOEK LAAK1, TOUL KAUK, PHNOM PENH
ទូរស័ព្ទ: (៨៥៥) ២៣ ៨៨៦ ៧០៨ / ទូរសារ: (៨៥៥) ២៣ ៨៨៦ ៧០០
Phone: (855) 23 886 708/ Fax: (885) 23 886 700